សួស្តីម្តងទៀត! នៅក្នុងរូបភាពនេះគឺនិយាយអំពីការក្រោកពីព្រលឹមដើម្បីដាក់បាត្រ។ ដោយរូបភាពទី ១ យើងឃើញមានស្ត្រីចំណាស់ម្នាក់ ដែលគាត់មានអាយុប្រហែលជាហាសិបឆ្នាំ គាត់ពាក់អាវពណ៌ស ដៃវែង និងសំពត់ពណ៌ស ត្រឹមស្មង[ខ្នង]ជើង។ គាត់ទើបតែ គាត់ក្រោក គាត់ក្រោកពីសម្រាន្តនៅពេលព្រឹកព្រលឹម។ អញ្ចឹងសម្រាប់មនុស្សចាស់យើងប្រើពាក្យ សម្រាន្ត យើងអត់ប្រើពាក្យគេងទេ គេងយើងប្រើសម្រាប់មនុស្សដែលមានអាយុប្រហែលយើង ប្អូនយើង ឬក៏ប្អូនយើង ឬក៏បងយើងបន្តិច យើងអាចប្រើពាក្យគេង ប៉ុន្តែសម្រាន្តយើងប្រើសម្រាប់មនុស្សចាស់។ អញ្ចឹងស្ត្រីម្នាក់ ស្ត្រីដែលនៅក្នុងរូបភាពទី ១ នោះ គឺគាត់ទើបតែក្រោកពីសម្រាន្តនៅពេលព្រឹកព្រលឹម ដោយយើងឃើញនៅក្នុងបន្ទប់គេងរបស់គាត់ យើងឃើញមានគ្រែមួយ មានពូកមួយ មានភួយ និងមានខ្នើយ។ អញ្ចឹងយើងឃើញខ្នើយ យើងប្រើសម្រាប់កើយ កើយក្បាលរបស់យើង ភួយយើងប្រើសម្រាប់ដណ្តប់ខ្លួន នៅពេលដែលយើងមានអារម្មណ៍ថារងា។ អញ្ចឹងយើង [...] យើងឃើញស្ត្រីចំណាស់ ដែលនៅក្នុងរូបភាពទីមួយនេះ គាត់ទើបតែភ្ញាក់ គាត់ទើបតែក្រោកពីសម្រាន្ត បន្ទាប់មក គាត់ក៏អង្គុយ គាត់ក៏អង្គុយនៅលើគ្រែរបស់គាត់ និងគាត់ពត់ខ្លួនរបស់គាត់ អញ្ចឹងដៃទាំងពីររបស់គាត់ ដៃខាងឆ្វេង និងដៃខាងស្តាំ លើកឡើងទៅលើដើម្បីពត់ខ្លួន ដើម្បីពត់ខ្លួន អញ្ចឹងគាត់មិនទាន់ក្រោកពីគ្រែនៅឡើយទេ គាត់ទើបតែ គាត់ពត់ខ្លួន គាត់ពត់ខ្លួនសិន បន្ទាប់មកទើបគាត់ក្រោកពីលើគ្រែ។ ដែលយើងឃើញ [...] ដែលយើងឃើញនៅខាងក្រៅបង្អួច យើងឃើញ យើងឃើញមានភ្នំ និងព្រះអាទិត្យដែលទើបនឹងរះ។ អញ្ចឹងជាទូទៅ នៅពេលព្រឹកព្រលឹមគឺមានព្រះអាទិត្យរះ នៅពេល គឺមានព្រះអាទិត្យរះនៅពេលព្រឹកព្រលឹម អញ្ចឹងស្ត្រីចំណាស់គាត់ក្រោកពីសម្រាន្តនៅពេលព្រឹកព្រលឹម និងអង្គុយនៅលើគ្រែ និងពត់ខ្លួនមួយសន្ទុះ។

បន្ទាប់មករូបភាពទី ២ រូបភាពទី ២ គាត់ក៏បានដើរចូលទៅក្នុងចង្ក្រានបាយ ឬក៏យើងអាចហៅបានថា ផ្ទះបាយ។ អញ្ចឹងចង្ក្រានបាយ និងផ្ទះបាយដូចគ្នា។ អញ្ចឹងស្ត្រីចំណាស់ម្នាក់នោះ គាត់ដើរចូលទៅក្នុងផ្ទះបាយ ដើម្បីដាំបាយ និងធ្វើម្ហូប។ អញ្ចឹងគាត់ដាំបាយនិងធ្វើម្ហូបក្នុងពេលតែមួយ ដើម្បីឲ្យទាន់ពេល ដាក់បាត្រលោកនៅពេលព្រឹក។ អញ្ចឹងស្ត្រីចំណាស់ម្នាក់នោះ គាត់ដាំបាយបណ្តើរ គាត់ធ្វើម្ហូបបណ្តើរ អញ្ចឹងមានឆ្នាំងពីរ មួយដាំបាយ ឆ្នាំងមួយទៀត គឺធ្វើម្ហូប ឬក៏ធ្វើសម្ល។ អញ្ចឹងយើងឃើញគាត់កាន់វែក កាន់វែកសម្លនៅក្នុងដៃរបស់គាត់ គាត់កំពុងតែកូរសម្ល ដោយយើងឃើញមានផ្សែងហុយចេញមកខាង យើងឃើញផ្សែងហុយចេញមកខាងក្រៅ ដែលធ្វើឲ្យយើងមានអារម្មណ៍ថាសម្លដែលស្ត្រី សម្លដែលគាត់ធ្វើគឺមានរសជាតិឆ្ងាញ់។ អញ្ចឹងគាត់ដាំបាយបណ្តើរ ធ្វើសម្លបណ្តើរ នៅក្នុងផ្ទះបាយរបស់គាត់។

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

បន្ទាប់មកទៀត រូបភាពទី ៣ រូបភាពទី ៣ ក្រោយពេលដែល ក្រោយពេលដែលម្ហូប ក្រោយពេលដែលម្ហូបនិងបាយរបស់គាត់ឆ្អិនហើយ គាត់ក៏បានប្រើវែក គាត់ក៏បានប្រើវែក ដួសបាយដាក់ចូលទៅក្នុង ដាក់ចូលទៅក្នុងថង់ ដើម្បីវេចខ្ចប់ ដើម្បីវេចខ្ចប់ ងាយស្រួលដាក់បាត្រលោក នៅពេលដែល នៅពេលដែលលោកនិមន្តមកកាត់ផ្ទះរបស់គាត់។ អញ្ចឹងយើងឃើញនៅលើតុ នៅក្នុងចង្ក្រានបាយរបស់គាត់មានថង់ពីរ ដែលថង់មួយគាត់បានប្រើវែកសម្ល ដួសសម្ល ដាក់ចូលទៅក្នុងថង់នោះ ថង់ទីពីរ [...] ថង់ទីពីរនៅលើតុនោះ គឺគាត់បានប្រើវែកបាយ ដួសបាយដាក់ចូលក្នុងថង់នោះ។ អញ្ចឹងគាត់បែកចែកជាពីរថង់ សម្លមួយថង់ បាយ បាយមួយថង់។ ដើម្បីកុំឲ្យ ដើម្បីកុំឲ្យ នៅពេលដែលយើងដាក់សម្ល និងបាយចូលគ្នា កុំឲ្យបាយរីក និងសម្លនៅពេលដែលដាក់ចូលទៅក្នុងបាយនិងទុករយៈពេលយូរ អាចធ្វើឲ្យសម្លនោះផ្អូម ឬក៏បាយនោះផ្អូម ដូច្នេះយើងអត់អាច ដូច្នេះយើងអត់អាចដាក់បាត្រលោក [...] យើងអត់អាចរាប់ យើងអត់អាចដាក់បាត្រដោយដាក់សម្ល និងបាយចូលគ្នាបានទេ។ អញ្ចឹងស្ត្រីចំណាស់ គាត់បានដួសបាយដាក់នៅក្នុង ដាក់កញ្ចប់មួយ ដួសសម្លដាក់កញ្ចប់មួយ។ ដោយសារតែបាយ និងសម្ល គាត់ទើបតែចម្អិន គាត់ទើបតែចម្អិនឆ្អិន យើងឃើញមានផ្សែងហុយ ហុយមកខាងលើ និងមានក្លិនឈ្ងុយ។

អញ្ចឹងរូបភាពទី ៤ រូបភាពទី ៤ ក្រោយពេលដែលគាត់បានដួសបាយដួសសម្លដាក់ចូលទៅក្នុងថង់ ដើម្បីវេចខ្ចប់រួចរាល់ហើយ គាត់ក៏បានដើរចេញមកខាងក្រៅ។ ដោយសារតែខាងក្រៅ នៅខាងក្រៅផ្ទះ មានដី ឬក៏ដុំថ្ម ដូច្នេះគាត់ត្រូវពាក់ស្បែកជើង ពីព្រោះនៅខាងក្រៅផ្ទះគឺមានដី ដូច្នេះប្រសិនបើគាត់អត់ពាក់ស្បែកជើង អាចធ្វើឲ្យជើងរបស់គាត់ប្រឡាក់ និងប្រសិនបើមានថ្ម គាត់ដើរនៅលើថ្ម អាចធ្វើឲ្យជើងរបស់គាត់ឈឺ។ អញ្ចឹងនៅពេលដែលនៅក្នុងផ្ទះគាត់ដោះស្បែកជើង នៅពេលដែលគាត់ដើរចេញមកខាងមុខផ្ទះ គឺគាត់ត្រូវពាក់ស្បែកជើង។ អញ្ចឹងស្ត្រីចំណាស់ដែលគាត់ពាក់អាវសដៃវែង សំពត់ស ត្រឹម សំពត់សត្រឹមស្មង[ខ្នង]ជើងនោះ គាត់បានយក គាត់បានដាក់តុមួយនៅខាងមុខផ្ទះគាត់ គាត់បានដាក់តុមួយនៅខាងមុខផ្ទះគាត់ បន្ទាប់មកគាត់ក៏បានយកកញ្ចប់បាយ និងសម្ល ដែលគាត់វេចខ្ចប់នោះយកមកដាក់លើតុ ដើម្បីរង់ចាំនៅពេលដែលព្រះសង្ឃនិមន្តដើរបិណ្ឌបាត្រ [...] កាត់មុខផ្ទះគាត់ គាត់អាច គាត់អាចដាក់ គាត់អាចដាក់បាត្រនូវបាយ ឬក៏ម្ហូបនោះ។ អញ្ចឹងស្ត្រីចំណាស់[...] ស្ត្រី ស្ត្រីចំណាស់នោះគាត់បានយក គាត់បានដាក់តុ នៅខាងមុខផ្ទះរបស់គាត់ និងយកកញ្ចប់ម្ហូប និងបាយដែលគាត់បានចម្អិន និងដួសរៀបចំដាក់ចូលនៅក្នុងកញ្ចប់នោះ ដើម្បីរៀបចំនៅពេលដែលព្រះសង្ឃនិមន្តកាត់ ព្រះសង្ឃនិមន្តកាត់ គាត់អាចដាក់បាត្របាន។

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

បន្ទាប់មកទៀតរូបភាពទី ៥ រូបភាពទី ៥ ស្ត្រីចំណាស់ម្នាក់នោះ
គាត់ក៏បានដើរចូលទៅក្នុងបន្ទប់ចៅស្រីរបស់គាត់។ ប៉ុន្តែចៅស្រីរបស់គាត់នៅគេងនៅឡើយទេ
ដោយសារតែព្រឹកពេក ចៅស្រីរបស់គាត់នៅក្មេង ដូច្នេះ ចៅស្រីរបស់គាត់ចូលចិត្តគេងច្រើន។
អញ្ចឹងយើងឃើញចៅស្រីរបស់គាត់គេងនៅលើគ្រែ ដែលកើយខ្នើយនៅលើក្បាល និងមាន
ដណ្ដាប់ភួយ និងមានដណ្ដាប់ភួយ។ អញ្ចឹងគាត់កំពុងតែគេងលង់លក់ស្រួល មិនទាន់ភ្ញាក់ដឹងខ្លួនទេ
ដោយសារតែគឺជាពេលព្រឹកព្រលឹម។ អញ្ចឹងគាត់អត់ចូលចិត្តក្រោកនៅពេលព្រឹកព្រលឹមទេ
អញ្ចឹងស្ត្រីចំណាស់ គាត់ក៏បានដើរចូលមកក្នុងបន្ទប់ចៅស្រីរបស់គាត់ ដើម្បី
ដើម្បីដាស់ចៅស្រីរបស់គាត់ឲ្យដឹងខ្លួន ដើម្បីដាស់ចៅស្រីរបស់គាត់ឲ្យដឹងខ្លួន
ឬក៏យើងអាចប្រើពាក្យដើម្បីហៅចៅស្រីរបស់គាត់ឲ្យភ្ញាក់ដឹងខ្លួន ដើម្បី ដើម្បីរៀបចំខ្លួន
ចេញទៅខាងក្រៅ ដាក់បាត្រ ដាក់បាត្រជាមួយនឹងគាត់។ អញ្ចឹងដោយសារតែគាត់ក្មេង
អញ្ចឹងគាត់ចូលចិត្តគេង អញ្ចឹងគាត់ចូលចិត្តគេងរហូតដល់ជីដូនគាត់ចេញ
រហូតដល់ជីដូនគាត់ចូលមកខាងក្នុងបន្ទប់របស់គាត់ដើម្បីហៅគាត់ ឬក៏ដាស់គាត់ឲ្យដឹងខ្លួន
ដើម្បីរៀបចំខ្លួន លុបមុខ ដុសធ្មេញ ចេញទៅខាងក្រៅដាក់បាត្រជាមួយនឹងគាត់។

បន្ទាប់មករូបភាពទី [៦] រូបភាពទី ៦ រូបភាពទី ៦ គាត់ក៏បានដាក់កៅអីពីរ នៅខាងមុខតុ
នៅមុខផ្ទះរបស់គាត់។ ដោយកៅអីមួយគាត់អង្គុយ កៅអីមួយទៀត ចៅស្រីរបស់គាត់អង្គុយ។
ពួកគាត់ទាំងពីរពាក់អាវដូចគ្នា ពណ៌ស ដៃវែង ប៉ុន្តែចៅស្រីរបស់គាត់ស្លៀកខោជើងវែង
ពណ៌ខ្មៅ និងស្ត្រីចំណាស់ម្នាក់នោះ គាត់ស្លៀកសំពត់ពណ៌ស ត្រឹមជង្គង់
និងមានពាក់ស្បែកជើងពណ៌ខ្មៅ និងចៅស្រីរបស់គាត់ ពាក់ស្បែកជើងពណ៌ស។
អញ្ចឹងពួកគាត់ទាំងពីរកំពុងតែអង្គុយដើម្បីរង់ចាំព្រះសង្ឃ និមន្តមក និមន្តមកផ្ទះរបស់គាត់
ដោយយើងឃើញនៅខាងក្រោយខ្នងរបស់គាត់ មានតុមួយ និងមានកញ្ច្រប់បាយ និងម្ហូប
ដើម្បីត្រៀមរាប់បាត្រនៅពេលដែលត្រៀមដាក់បាត្រនៅពេលដែលព្រះសង្ឃនិមន្តកាត់ផ្ទះរបស់គាត់។

បន្ទាប់មកទៀតរូបភាពទី ៧ រូបភាពទី ៧ ព្រះសង្ឃក៏បាននិមន្តមក
ព្រះសង្ឃក៏បាននិមន្តកាត់ផ្ទះរបស់គាត់។
ជាទូទៅព្រះសង្ឃតែងតែនិមន្តបិណ្ឌបាត្រនៅពេលព្រឹកព្រលឹមដើម្បី ដើម្បីបិណ្ឌបាត្រយកម្ហូប
យកបាយ ទុកឆាន់នៅពេលថ្ងៃត្រង់ ទុកឆាន់នៅពេលថ្ងៃត្រង់។ អញ្ចឹងជាទូទៅ
ជាទូទៅព្រះសង្ឃត្រូវក្រោកពីព្រលឹមដើម្បីដើរបិណ្ឌបាត្រ ដើម្បីដើរបិណ្ឌបាត្របាយ
ឬក៏ម្ហូបទុកឆាន់នៅពេលថ្ងៃត្រង់។ អញ្ចឹងពាក្យថាឆាន់ដូចជាពាក្យថាញ៉ាំ
ប៉ុន្តែយើងប្រើសម្រាប់ព្រះសង្ឃ យើងប្រើពាក្យឆាន់ យើងអត់ប្រើពាក្យញ៉ាំទេ។

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

អញ្ចឹងព្រះសង្ឃយើងឃើញគ្រងនូវស្បង់ចីពរពណ៌ ពណ៌លឿង
ព្រះសង្ឃអត់ស្លៀកពាក់ខោអាវដូចជាយើងទេ។ ព្រះសង្ឃគ្រងនូវ គ្រងនូវស្បង់ចីពរពណ៌លឿង
និងព្រះសង្ឃត្រូវកោរសក់ ត្រូវកោរសក់ នៅក្នុងដៃរបស់ព្រះសង្ឃគឺមានបាត្រ គឺមានបាត្រ។
គឺបាត្រមានរាងមូល និងប្រើសម្រាប់ដាក់បាយ ឬក៏ដាក់ម្ហូប និងព្រះសង្ឃ
គឺនិមន្តដើរដោយអត់ពាក់ស្បែកជើង។ អញ្ចឹងជាទូទៅ នៅពេលដែលព្រះសង្ឃនិមន្តដើរបិណ្ឌបាត្រ
ព្រះសង្ឃអត់ពាក់ស្បែកជើងទេ។ នៅខាងក្រោយព្រះសង្ឃ យើងឃើញមានកូនសិស្សលោកម្នាក់
យើងឃើញមានកូនសិស្សលោកម្នាក់ ដោយយើងឃើញក្មេងប្រុសនោះ មានពាក់អាវស ដៃខ្លី
និងខោពណ៌ស ជើងខ្លី។ និងក្មេង ក្មេងប្រុសដែលជាកូនសិស្សរបស់លោក យើងឃើញមានយួរ
មានយួរនូវចង់យាមនៅចំហៀងខ្លួនរបស់គាត់ ដែលចង់យាមនោះបើយើងនិយាយពី
ប្រសិនបើយើងនិយាយក្រៅពីព្រះសង្ឃ យើងហៅថាកាបូប យើងហៅថាកាបូប
ប៉ុន្តែសម្រាប់ព្រះសង្ឃយើងហៅថាចង់យាមយើងហៅថាចង់យាម។ អញ្ចឹងចង់យាម
ប្រើសម្រាប់ដាក់លុយ ឬក៏ដាក់បង្អែម ឬដាក់ផ្លែឈើ នៅពេលដែល នៅពេលដែលប្រជាជន
គាត់បានរាប់បាត្រ គាត់បានដាក់បាត្រនាពេលព្រឹក។ អញ្ចឹងយើងឃើញក្មេង
យើងឃើញកូនសិស្សលោកនោះ កំពុងតែ កូនសិស្សលោកកំពុងតែដើរតាមពីក្រោយលោក
ដើរតាមពីក្រោយលោក ឬក៏ព្រះសង្ឃ។ អញ្ចឹងព្រះសង្ឃយើងអាចហៅ
យើងអាចនិយាយពាក្យព្រះសង្ឃ ឬក៏យើងអាចហៅថាលោកសង្ឃ ឬក៏លោក។ អញ្ចឹង
អញ្ចឹងកូនសិស្សលោកដើរតាម ដើរតាមលោកពីក្រោយដើម្បីបិណ្ឌបាត្រ [...] ដើម្បី ដើម្បីបិណ្ឌបាត្រ
ម្ហូបនិង ម្ហូបនិងបាយទុកឆាន់នៅពេល ទុកឆាន់នៅពេលថ្ងៃត្រង់។
កូនសិស្សលោកគឺជាអ្នកដែលរស់នៅក្នុងវត្ត ដែលទុកវត្តដូចជាផ្ទះរបស់គាត់ដែរ
ដោយគាត់រស់នៅនៅក្នុងវត្ត គាត់ញ៉ាំបាយនៅក្នុងវត្ត គាត់រៀន គាត់រៀន ឬក៏គាត់រស់នៅនៅក្នុងវត្ត
អញ្ចឹងវត្តដូចជាផ្ទះរបស់គាត់ដែរ និងគាត់ជួយធ្វើកិច្ចការវត្តខ្លះ។ អញ្ចឹងយើងហៅថាកូនសិស្ស
លោក។

បន្ទាប់មកទៀតរូបភាពទី រូបភាពទី ៨ រូបភាពទី ៨
ក្រោយពេលដែលព្រះសង្ឃនិមន្តកាត់ផ្ទះរបស់ស្ត្រីចំណាស់ និងចៅរបស់គាត់ ព្រះសង្ឃក៏បានឈប់
ដើម្បីឲ្យស្ត្រី ដើម្បីឲ្យស្ត្រីម្នាក់នោះគាត់អាចដាក់បាត្រ គាត់អាចដាក់បាត្រ។ អញ្ចឹងព្រះសង្ឃឈប់
និងព្រះសង្ឃ [...] ព្រះសង្ឃកាន់បាត្រ កាន់បាត្រនៅក្នុងដៃ
និងកូនសិស្សលោកគឺដើរពីក្រោយព្រះសង្ឃដែលមានយួរនូវចង់យាមរបស់ព្រះសង្ឃ។
អញ្ចឹងយើងឃើញ ពួក ពួកគាត់ទាំងពីរ ពួកគាត់ទាំងពីរស្ត្រីចំណាស់ និងចៅស្រីរបស់គាត់
ក្រោយពេលដែលពួកគាត់ទាំងពីរបានឃើញព្រះសង្ឃ និមន្តមកផ្ទះរបស់គាត់ ពួកគាត់ទាំងពីរក៏បាន
ក៏បានក្រោក ក្រោកពីកៅអី ក្រោកពីកៅអី និងបានដោះស្បែកជើង និងបានក្រាលកម្រាល

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

និងបានក្រាលកម្រាលនៅលើ ក្រាលកម្រាលនៅលើដី ដើម្បីអង្គុយលុតជង្គង់។ អញ្ចឹងជាទូទៅ
នៅពេលដែលយើងរាប់បាត្រ យើងមិនអាចពាក់ស្បែកជើងបានទេ
ពីព្រោះនៅពេលដែលយើងពាក់ស្បែកជើង គឺមានន័យថាយើង គឺអាចធ្វើឲ្យយើងបាបបាន
បាបមានន័យថា មានន័យថា បើទោះបីជាយើងធ្វើល្អ ប៉ុន្តែដោយសារតែយើង
ដោយសារតែយើងពាក់ស្បែកជើង ដោយសារតែពាក់ស្បែកជើង មិនគោរពព្រះសង្ឃ
ដូច្នេះអាចយើង អាចធ្វើឲ្យយើងជួបនឹងរឿងអាក្រក់បាន។ អញ្ចឹងយើង មនុស្សទាំងអស់
នៅពេលដែលដាក់បាត្រលោក ត្រូវតែដោះស្បែកជើង
ដោយសារតែព្រះសង្ឃក៏ដោះស្បែកជើងដូចគ្នាដែរ។ អញ្ចឹងនៅពេលដែលយើងដាក់បាត្រ
យើងត្រូវដោះស្បែកជើងដូចគ្នាដែរ ពីព្រោះយើងគិតថាប្រសិនបើយើងពាក់ស្បែកជើង អាច អាច
យើងអាចខ្ពស់ជាងព្រះសង្ឃ អញ្ចឹងជាទូទៅ យើងមិនអាចអង្គុយ ឬក៏យើងមិនអាចឈរដាក់បាត្រ
ខ្ពស់ជាងព្រះសង្ឃបានទេ។ អញ្ចឹងអ្នកទាំងពីរត្រូវដោះស្បែកជើងចេញដើម្បី
ត្រូវដោះស្បែកជើងចេញដើម្បីដាក់បាត្រ ពីព្រោះប្រសិនបើនៅពាក់ស្បែកជើង [...] ពីព្រោះប្រសិនបើ
ពីព្រោះប្រសិនបើពាក់ស្បែកជើងនៅពេលដែលរាប់បាត្រ អាច អាចធ្វើឲ្យគាត់មានបាប
អាចធ្វើឲ្យគាត់បាប ឬក៏យើងគិតថានៅពេលដែលគាត់ពាក់ស្បែកជើងរាប់បាត្រ
គឺគាត់ខ្ពស់ជាងលោក គឺគាត់ខ្ពស់ជាងលោក និងអាចមានបាប អញ្ចឹងគាត់ត្រូវដោះស្បែកជើងចេញ
និងអង្គុយលុតជង្គង់ ធ្វើយ៉ាងណាឲ្យទាបជាងព្រះសង្ឃ ធ្វើយ៉ាងណាឲ្យទាបជាងព្រះសង្ឃ។
អញ្ចឹងអ្នកទាំងពីរ ស្ត្រីចំណាស់ និងចៅស្រី អង្គុយលុតជង្គង់នៅលើកម្រាល
ដែលដាក់ក្រាលនៅលើដី។ អញ្ចឹងពួកគាត់ទាំងពីរបានយកកញ្ចប់ដែលមានបាយនិងម្ហូបនោះ
កាន់នៅក្នុងដៃទាំងពីររបស់គាត់ ដើម្បីរៀបចំដាក់បាត្រ ដើម្បីរៀបចំដាក់បាត្រ។

បន្ទាប់មកទៀត រូបភាពទី បន្ទាប់មកទៀតរូបភាពទី ៩ រូបភាពទី ៩ ក្រោយពេលដែលស្ត្រីចំណាស់
និងក្មេងស្រី ដែលជាចៅស្រីរបស់គាត់បានដោះស្បែកជើង និងលុតជង្គង់នៅលើកម្រាល
ដែលក្រាលនៅលើដី នៅពេលដែលគាត់លុតជង្គង់ គាត់ត្រូវថ្វាយបង្គំព្រះសង្ឃចំនួនបីដងសិន
គាត់ត្រូវថ្វាយបង្គំព្រះសង្ឃចំនួនបីដងសិន មុនពេលដែល មុនពេលដែលដាក់បាត្រ
មុនពេលដែលដាក់បាត្រ។ អញ្ចឹងគាត់ត្រូវគោរពព្រះសង្ឃដោយថ្វាយបង្គំព្រះសង្ឃចំនួនបីដង
បន្ទាប់មកពួកគាត់ទាំងពីរ [...] ជាមួយនឹងចៅស្រី គាត់ក៏បានក្រោកអង្គុយចោងហោង
គាត់ក៏បានក្រោកអង្គុយចោងហោង និងដាក់ដៃទាំងពីរផ្តុំគ្នា ដោយដាក់កញ្ចប់
នៅលើដៃទាំងពីររបស់គាត់ និងលើកឡើងលើ ដោយគាត់កំពុងតែ គាត់កំពុងតែប៉ងប្រាថ្នា
មានន័យថាមុនពេលដែលរាប់បាត្រ យើង យើងត្រូវមាន យើងត្រូវនិយាយនៅក្នុងចិត្តរបស់យើង
នូវបំណងប្រាថ្នាដែលយើងចង់បាន អញ្ចឹងគាត់កំពុងតែ គាត់កំពុងតែប៉ងប្រាថ្នា
ដែលប្រហែលជាគាត់ចង់មានសេចក្តីសុខ ប៉ងប្រាថ្នាសុំសេចក្តីសុខ និងរកស៊ីមានបាន

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

និងកុំឲ្យមានជំងឺ អញ្ចឹងជាទូទៅនៅមុនពេលដែលយើងដាក់បាត្រយើងត្រូវប៉ងនៅក្នុងចិត្តសិន។ អញ្ចឹងអ្វីដែលយើង យើងត្រូវប៉ងនិងសុំ អ្វីដែលយើងចង់បាន។ ដូចជាយើងចង់ ប្រសិនបើយើងចង់សុំឲ្យមានសុខភាពល្អ យើងចង់សុំឲ្យមានលុយច្រើន ឬក៏មានការងារធ្វើ ឬក៏ជួបមនុស្សដែលល្អៗ អញ្ចឹងជាទូទៅ មុនពេលដាក់បាត្រ គាត់ត្រូវផ្សង គាត់ត្រូវផ្សង ឬក៏ប៉ង ឬក៏ ឬក៏ប៉ងប្រាថ្នាអ្វីមួយនៅក្នុងចិត្តរបស់គាត់ និងនិយាយនៅក្នុងចិត្តរបស់គាត់ អញ្ចឹងគាត់ផ្សង ឬក៏គាត់ប៉ងនៅក្នុងចិត្តរបស់គាត់ ឬក៏ប្រាថ្នានៅក្នុងចិត្តរបស់គាត់មុនពេលដែលដាក់បាត្រ មុនពេលដែលដាក់បាត្រ។ អញ្ចឹងក្រោយពេលដែលពួកគាត់ទាំងពីរបានប៉ងប្រាថ្នារួចរាល់ហើយ បានប៉ងប្រាថ្នា ឬក៏ផ្សងរួចរាល់ហើយ ឬក៏ផ្សងរួចរាល់ហើយ។

នៅក្នុងរូបភាពទី នៅក្នុងរូបភាពទី ១០ រូបភាពទី ១០ នៅក្នុងរូបភាពទី ១០ ព្រះសង្ឃក៏បានបើកគម្របបាត្រ ព្រះសង្ឃក៏បានបើកគម្របបាត្រ ដើម្បីឲ្យស្ត្រីចំណាស់ និងចៅស្រីរបស់គាត់ អាចដាក់បាយ ម្ហូប ចូលទៅខាងក្នុងបាន អញ្ចឹងអាចដាក់បាយនិងម្ហូបចូលទៅខាងក្នុងបាន។ អញ្ចឹងព្រះសង្ឃបាន[...] ព្រះសង្ឃបានបើកបាត្រដែលកាន់នៅក្នុងដៃរបស់ព្រះសង្ឃទាំងពីរ។

បន្ទាប់មកទៀតរូបភាពទី [១១] រូបភាពទី ១១ រូបភាពទី ១១ ក្រោយពេលដែលស្ត្រីចំណាស់ គាត់បានប៉ងប្រាថ្នា ឬក៏ផ្សងរួចរាល់ហើយ គាត់ក៏បានក្រោកឡើង និងបានយកកញ្ចប់បាយ កញ្ចប់បាយដែលគាត់រៀបចំ និងប៉ងប្រាថ្នានោះ យកមកដាក់ចូលទៅក្នុងបាត្ររបស់ព្រះសង្ឃ នៅពេលដែលព្រះសង្ឃបានបើកបាត្រនោះ។ អញ្ចឹងគាត់ក៏បានដើរចូលមកដាក់ បាយសម្ល ឬក៏បាយម្ហូបដែលគាត់បានចម្អិននៅពេលព្រឹកនោះ គាត់ក៏បានដាក់ចូលទៅក្នុងបាត្ររបស់លោក។

បន្ទាប់មកទៀតរូបភាពទី រូបភាពទី ១២ ក្រោយពេល រូបភាពទី ១២ ក្រោយពេលដែល ស្ត្រីចំណាស់បានដាក់បាយនិងម្ហូបនៅក្នុងបាត្ររួចរាល់ហើយ ព្រះសង្ឃក៏បានយកគម្របបាត្រនោះគ្របវិញ ព្រះសង្ឃក៏បានយកគម្របបាត្រនោះគ្របឲ្យជិតវិញ។

បន្ទាប់មកទៀតរូបភាពទី រូបភាពទី ១៣ ក្រោយពេលដែល រូបភាពទី ១៣ ក្រោយពេលដែលស្ត្រីចំណាស់ និងក្មេងស្រី បាន បានដាក់ម្ហូបបាយចូលទៅក្នុងបាត្រ របស់លោករួចរាល់ហើយ ពួកគាត់ទាំងពីរទៅថយក្រោយមកអង្គុយនៅលើកម្រាលដែល [...] ដែលក្រាល [...] ដែលគាត់ក្រាលនៅលើដី  និងគាត់បានដោះស្បែកជើងដាក់នៅខាង ដាក់នៅខាងក្រោយរបស់គាត់ គាត់ត្រូវលើកដៃសំពះដើម្បីទទួលពរពីព្រះសង្ឃ។ អញ្ចឹងព្រះសង្ឃគាត់បានសូត្រធម៌ដើម្បីឲ្យពរទៅកាន់ ទៅកាន់ស្ត្រីចំណាស់ និងក្មេងស្រី។

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

អញ្ចឹងជាទូទៅព្រះសង្ឃនៅពេលដែល នៅពេលដែលប្រជាជនគាត់ដាក់បាត្រ ដាក់បាយសម្ល ឬក៏លុយ ព្រះសង្ឃត្រូវសូត្រធម៌ ឬក៏ឲ្យពរ ទៅកាន់ប្រជាជន។ អញ្ចឹងជាក់ស្ដែង នៅក្នុងរូបភាពទីដប់ ដប់បីនេះ ក្រោយពេលដែលស្ត្រីចំណាស់ និងក្មេងស្រីបាន បានថយមកខាងក្រោយនិងអង្គុយសំពះដើម្បីទទួលពរពីព្រះសង្ឃ ព្រះសង្ឃក៏បានឲ្យពរ និង [...] និងសូត្រធម៌មួយចំនួន ដើម្បីឲ្យពរទៅកាន់អ្នកទាំងពីរ។ និងក្មេង និងក្មេងប្រុសដែលជាកូនសិស្សលោក គឺនៅឈរខាងក្រោយលោក ដើម្បីរង់ចាំឲ្យលោកសូត្រធម៌ ឬក៏ឲ្យពររួចរាល់ហើយ បន្ទាប់មកអាចបន្តដំណើរទៅមុខទៀត។

បន្ទាប់មកទៀតរូបភាពទី ១៤ រូបភាពទី ១៤ ព្រះសង្ឃក៏បានសូត្រធម៌ និងបានឲ្យពរទៅកាន់អ្នកទាំងពីរ ដោយយើងឃើញមាត់របស់ព្រះអង្គកំពុងតែសូត្រធម៌ ឬក៏ឲ្យពរ ឬក៏ឲ្យពរ។

បន្ទាប់មកទៀតរូបភាពទី ១៥ រូបភាពទី ១៥ ដោយសារតែ ដោយសារតែ មានមនុស្សគាត់រាប់បាត្រច្រើន គាត់រាប់បាត្រច្រើននៅពេលព្រឹកនេះ ឬក៏មានមនុស្សគាត់ដាក់បាត្រច្រើននៅពេលព្រឹកនេះ ធ្វើឲ្យបាត្រ និងដោយសារតែបាត្រ បាត្ររបស់លោក គឺតូចផង ដូច្នេះក្រោយពេលដែលស្ត្រីចំណាស់ និងក្មេងស្រីបានដាក់បាយ និងម្ហូបចូលទៅខាងក្នុងនោះ ធ្វើឲ្យបាត្រនោះពេញ ធ្វើឲ្យបាត្រនោះពេញ ដូច្នេះព្រះសង្ឃត្រូវបើក ត្រូវបើកបាត្រនោះដើម្បីយកបាយសម្លនោះដាក់ចូលទៅក្នុងថង់យាម ដោយក្មេងប្រុសបានស្ពាយនៅចំហៀងខ្លួនរបស់គាត់។ អញ្ចឹងក្មេងប្រុសក្រោយពេលដែលព្រះសង្ឃបានបើកបាត្រនោះ ក្មេងប្រុសក៏បានលូកដៃ យកបាយនិងម្ហូបនោះ ដើម្បីដាក់ចូលទៅក្នុងថង់យាម ដើម្បីឲ្យបាត្រនោះស្រាល និងទំនេរ ស្រាល និងទំនេរ។

បន្ទាប់មកទៀត រូបភាពទី រូបភាពទី ១៦ ព្រះសង្ឃក៏បានបន្តនិមន្តទៅផ្ទះប្រជាជនផ្សេងទៀត ដើម្បី ដើម្បីនិមន្តបិណ្ឌបាត្រ ដើម្បីបិណ្ឌបាត្រ អញ្ចឹងយើងឃើញព្រះសង្ឃនិមន្តនៅ ព្រះសង្ឃនិមន្តខាងមុខក្មេងប្រុស ដោយព្រះសង្ឃមានកាន់បាត្រនៅក្នុងដៃ ព្រះសង្ឃនិមន្តដោយដោះស្បែកជើង និងក្មេងប្រុសមានកាន់ថង់យាម [ដោយ]មានដាក់ម្ហូប ដែលមានដាក់ម្ហូបបាយដែលស្ត្រីចំណាស់ និងចៅស្រីរបស់គាត់បានដាក់បាត្រអម្បាញ់មិញ អញ្ចឹងគាត់បានប្រមូលដាក់ចូលទៅក្នុងថង់យាម ដែលគាត់ស្ពាយនៅចំហៀងខ្លួនរបស់គាត់ និងក្មេងប្រុសដែលជាកូនសិស្សលោកនោះ បានដើរតាមពីក្រោយ បានដើរតាមពីក្រោយលោកជានិច្ច។

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

បន្ទាប់មកទៀតរូបភាពទី រូបភាពទី ១៧ រូបភាពទី ១៧ ក្រោយពេលដែលស្ត្រីចំណាស់ និងចៅស្រីរបស់គាត់បានដាក់បាត្ររួចរាល់ហើយ និងក្រោយពេលដែលព្រះសង្ឃនិមន្ត ព្រះសង្ឃនិមន្ត ព្រះសង្ឃនិមន្តទៅ ឬក៏ព្រះសង្ឃនិមន្តទៅផ្ទះប្រជាជនផ្សេងទៀត [...] ស្ត្រីចំណាស់ក៏បានក្រោកឡើង ស្ត្រីចំណាស់ក៏បានក្រោកឈរ និងពាក់ស្បែកជើង និងបានយកក្រណាត់ដែលដាក់នៅលើដី ដើម្បី ដើម្បីអង្គុយ ដើម្បីអង្គុយ ដើម្បីអង្គុយដាក់បាត្រនោះ អញ្ចឹងស្ត្រីចំណាស់ ក៏បានលើកក្រណាត់នោះឡើងមកខាងលើ ដើម្បីបត់ក្រណាត់នោះ និង ដើម្បីបត់ក្រណាត់នោះ ដើម្បីយកទៅទុកនៅក្នុងផ្ទះវិញ។ និងយើងឃើញចៅស្រីរបស់គាត់អង្គុយកំពុងតែពាក់ស្បែកជើង ដោយសារតែស្បែកជើងចៅស្រីរបស់គាត់ គឺស្បែកជើងប៉ាតា ដូច្នេះពិបាកបន្តិច គាត់ត្រូវអង្គុយពាក់ស្បែកជើងសិន ប៉ុន្តែស្បែកជើងរបស់ស្ត្រីចំណាស់គឺស្បែកជើងស៊ក ដូច្នេះគាត់ [...] គាត់គ្រាន់តែ [...] ស៊កជើងចូល អញ្ចឹងគាត់ពាក់បានយ៉ាងងាយស្រួល ស្បែកជើង ចំណែកស្បែកជើងក្មេងស្រី គឺស្បែកជើងប៉ាតា អញ្ចឹងគាត់ត្រូវអង្គុយចំណាយពេលពាក់បន្តិច អញ្ចឹងគាត់អង្គុយនិងគាត់លើកជើងរបស់គាត់ដើម្បីពាក់ស្បែកជើង។

បន្ទាប់មកទៀតរូបភាពចុងក្រោយ រូបភាពចុងក្រោយ រូបភាពទី ១៨ ក្រោយពេលដែលក្មេងស្រីដែលជាចៅស្រីរបស់ស្ត្រីចំណាស់នោះ គាត់ពាក់ស្បែកជើងរួចរាល់ហើយ ពួកគាត់ទាំងពីរក៏បាន ពួកគាត់ទាំងពីរក៏បានយកក្រណាត់ដែលបានដាក់នៅលើ[...] ដែលបានដាក់នៅលើដីដើម្បី ដាក់បាត្រអម្បាញ់មិញ គាត់បានរុំក្រណាត់នោះមូល មូលមួយដុំ គាត់បានមូរក្រណាត់នោះ បន្ទាប់មកគាត់ គាត់ត្បៀតក្រដាស ក្រណាត់នោះនឹងដៃរបស់គាត់ ជាប់នឹងខ្លួនរបស់គាត់។ អញ្ចឹងគាត់ត្បៀតក្រណាត់នោះដាក់ជាប់នឹងខ្លួន និងដៃរបស់គាត់ បន្ទាប់មកគាត់ក៏ដើរចូល គាត់ក៏បានដើរត្រលប់ចូលទៅក្នុងផ្ទះរបស់គាត់វិញ។ ដោយស្ត្រីចំណាស់ដើរនាំមុខ និងចៅស្រីរបស់គាត់ដើរពីក្រោយស្ត្រីចំណាស់ម្នាក់នោះ។ អញ្ចឹងចៅស្រីរបស់គាត់ដើរពីក្រោយយាយរបស់គាត់។ អញ្ចឹងស្ត្រីចំណាស់ គាត់ហៅក្មេងស្រីនោះចៅ និងក្មេងស្រីគាត់ហៅស្ត្រីចំណាស់នោះយាយ។ អញ្ចឹងយាយនិងចៅក៏បានដើរចូលទៅក្នុងផ្ទះវិញ ដោយពួកគាត់បានក្រោកពីព្រលឹម ដើម្បីរាប់ ដើម្បីដាក់បាត្រ ដោយ ដោយក្រោយពេលដែលដាក់បាត្ររួចរាល់ហើយ ពួកគាត់ទាំងពីរមានអារម្មណ៍ថាស្រស់ស្រាយ ដោយសារតែពួកគាត់ទាំងពីរបានក្រោកពីព្រលឹម ដើម្បីធ្វើបុណ្យ និងបុណ្យទាំងអស់នោះនឹងធ្វើឲ្យគាត់ជួបតែសំណាងល្អ និងជួបអ្វីដែលល្អៗជានិច្ច។

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.